01179650

E378

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 12 / 2015
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥

ផ្ញើជូន៖ ប្រធានគណៈមេធាវីទីក្រុងអាំស្ទែរដាំ

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

កម្មវត្ថុ៖ កំហុសវិជ្ជាជីវៈរបស់មេធាវី ០១ រូប ដែលបានចុះបញ្ជីនៅគណៈមេធាវីរបស់លោក/លោកស្រី

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.") គឺជាតុលាការមួយដែលត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម។ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក កំពុងជំនុំជម្រះលើសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹង នួន ជា ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និង អំពើប្រល័យពូជសាសន៍។ ខ្ញុំសូមភ្ជាប់មកជាមួយនូវគេហទំព័ររបស់ អ.វ.ត.ក. ស្តីពីឯកសារក្របខ័ណ្ឌរបស់ អ.វ.ត.ក. សម្រាប់ជាការសម្អាងរបស់លោក/លោកស្រី។

- ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក:
  http://www.eccc.gov.kh/sites/default/files/legal-documents/KR_Law_as_amended_27_Oct_2004_Eng.pdf
- វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក:
  http://www.eccc.gov.kh/en/document/legal/internal-rules-rev8

លោក Victor KOPPE ដែលជាសមាជិកគណៈមេធាវីទីក្រុងអាំស្ទែរដាំ កំពុងតែធ្វើជាមេធាវីការពាររបស់លោក នួន ជា ក្នុងសំណុំរឿង ០០២/០២។

នៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីសវនាការកាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ កន្លងទៅនេះ លោក Victor KOPPE បានធ្វើការជំទាស់ទៅនឹងការប្រើប្រាស់ឯកសារមួយចំនួនពីសំណាក់សហព្រះរាជអាជ្ញា ។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការជំទាស់នេះ។ ក្រោយពីអង្គជំនុំជម្រះបានបញ្ជាក់ពីការជំទាស់របស់ខ្លួនរួចមក លោក KOPPE បានបកស្រាយកិច្ចដំណើរការនីតិវិធីនេះថា ជាការគួរឱ្យអស់សំណើច និង បានលើកឡើងថា គាត់អាចនឹង "ដកខ្លួនជាផ្លូវការ" ចេញពីការជំនុំជម្រះនេះ។ លោក KOPPE បានដើរចេញពីបន្ទប់សវនាការ ហើយសហមេធាវីជាតិរបស់គាត់ក៏បានដើរចេញតាមក្រោយផងដែរ។ ដោយយល់ឃើញថា មិនអាចបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានវត្តមានមេធាវីការពារក្តី អង្គជំនុំជម្រះក៏បានផ្អាកកិច្ចដំណើរការនីតិវិធី[1]។

នៅថ្ងៃបន្ទាប់ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យមេធាវីការពារក្តីផ្តល់នូវហេតុផល និង មូលដ្ឋានគតិយុត្តិចំពោះការប្រព្រឹត្តិរបស់ពួកគាត់ (ភ្ជាប់មកជាមួយ ឯកសារ E361)។ ជាការឆ្លើយតប ទោះបីជាទទួលស្គាល់ថា ពុំមានមូលដ្ឋានគតិយុត្តិចំពោះការដកខ្លួនចេញរបស់គាត់ពីកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏លោក KOPPE *ក្នុងចំណោមប្រការផ្សេងទៀត* បានថ្លែងដូចខាងក្រោមនេះ៖

- លើកឡើងម្តងទៀតនូវសេចក្តីបញ្ជាក់កាលពីមុនរបស់ក្រុមមេធាវីការពារក្តី នួន ជា ថា ចៅក្រមម្នាក់ក្នុងចំណោមចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺចៅក្រម LAVERGNE "បានធ្វើសេចក្តីសម្រេចបែបកំសាក និង ពុំមានសុចរិតភាពផ្នែកតុលាការឡើយ"[2]។
- ជម្រាបទៅចៅក្រម FENZ ថា គាត់សោកស្តាយ "យ៉ាងខ្លាំង" ចំពោះសេចក្តីសម្រេចរបស់ក្រុមរបស់គាត់ដែលមិនប្តឹងជំទាស់លោកស្រី និង អះអាងថា ប្រៀបធៀបទៅនឹងបទពិសោធន៍ដែលទទួលបាននៅក្នុងសវនាការសំណុំរឿង ០០២/០២ "ចៅក្រម CARTWRIGHT គឺពិតជាពន្លឺនៃភាពមិនលម្អៀងដ៏ភ្លឺត្រចះត្រចង់"[3]។
- អះអាងថា "លោកប្រធាន ជាការពិតហើយថា វាជាបុព្វសិទ្ធិរបស់លោកប្រធាន ដែលត្រូវដែលលោកអាច -- លោកប្រធានកាត់ផ្តាច់ខ្ញុំដូច្នេះ ខ្ញុំគ្មានអ្វីនិយាយតទៅទៀតទេ។ ដូច្នេះ គ្មានជម្រើសទេ"[4]។
- ឆ្លើយតបទៅនឹងចៅក្រម LAVERGNE "ខ្ញុំចង់ផ្តល់មូលហេតុ ប៉ុន្តែលោកអត់ព្រមស្តាប់ខ្ញុំទេ លោកចៅក្រម"[5]។

---

[1] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ២៥-២៧, ៣៤-៤០។

[2] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥, p. 12. ទំព័រ ៩។

[3] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ p. 12. ទំព័រ ៩។

[4] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥, p. 14. ទំព័រ ១១។

01179652

E378

- ជម្រាបទៅចៅក្រម LAVERGNE "និយាយដោយស្មោះត្រង់ទៅ គឺថាខ្ញុំមិនយកចិត្តទុកដាក់នូវអ្វីដែលលោកកំពុងតែគិតទេ"[6] និង
- កត់សម្គាល់ថា ប្រសិនបើ អ.វ.ត.ក គឺជាតុលាការដែលអនុវត្តច្បាប់កុំមិនឡ ហើយ "ខ្ញុំត្រូវបានចោទប្រកាន់ថាមាក់ងាយដល់តុលាការ ខ្ញុំរីករាយទទួលកំហុស។ តាមពិត ខ្ញុំគ្មានអី ក្រៅតែពីមិនឲ្យតម្លៃផ្នែកវិជ្ជាជីវៈចំពោះចៅក្រមអន្តរជាតិនៃតុលាការនេះ"[7]។

នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ឱកាសបន្ថែមទៀតឲ្យលោក KOPPE កែតវិយាបថរបស់គាត់ និង បានកត់សម្គាល់ថា ប្រសិនបើគាត់មិនកែតវិយាបថរបស់គាត់នោះទេ អង្គជំនុំជម្រះគ្មានជម្រើសអ្វីក្រៅតែពីការចាត់វិធានការមួយចំនួននោះទេ[8]។ រហូតមកដល់ពេលនេះ លោក KOPPE មិនបានប្រើប្រាស់ឱកាសដែលបានផ្តល់ឲ្យគាត់នោះទេ។

តាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ឥរិយាបថរបស់លោក KOPPE បង្ហាញឲ្យឃើញថាជាកំហុសវិជ្ជាជីវៈ ដូចមានចែងនៅក្នុងវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះបានសម្រេចបញ្ជូនបញ្ហានេះទៅគណៈមេធាវីអាំស្ទែដាំ អនុលោមតាមវិធាន ៣៨(២) នៃវិធានផ្ទៃក្នុង។ យោងទៅលើហេតុផលនេះ ខ្ញុំបានភ្ជាប់មកជាមួយនូវប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី និង តំណភ្ជាប់ (Links) សម្រាប់ចូលទៅមើលឯកសារវីដេអូ នៅក្នុងសំណុំរឿង ០០២/០២ ពីថ្ងៃទី ២៦ ដល់ថ្ងៃទី ២៧ ខែ សីហា និងថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥។ ខ្ញុំសូមអរគុណ ប្រសិនបើលោក/លោកស្រីអាចជម្រាបមកអង្គជំនុំជម្រះសាលាដំបូង នៅក្នុងរយៈពេលសមស្រប អំពីលទ្ធផលនៃការបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះ និង វិធានការដែលត្រូវអនុវត្តចំពោះកំហុសនេះ តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង។

ប្រសិនបើលោក/លោកស្រីមានចម្ងល់អ្វីបន្ថែមទៀត ឬ ត្រូវការព័ត៌មានបន្ថែមទៀតពីអង្គជំនុំជម្រះសាលាដំបូង សូមទំនាក់ទំនង ៖

Ken Roberts (roberts13@un.org)
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
PO Box 71
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[5] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥, p. 16. ទំព័រ ១២។

[6] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥, p. 16. ទំព័រ ១២។

[7] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥. ទំព័រ ១៤។

[8] ប្រតិចារឹកសវនាការ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៤១។